ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអភិវឌ្ឍន៍ជនបទ

## Ministry of Rural Development



# សៀវភៅថវិកាពលរដ្ឋ ឆ្នាំ២០២៦

## Citizen Budget Fiscal Year 2026

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងអភិវឌ្ឍន៍ជនបទ

Ministry of Rural Development

# សៀវភៅថវិកាពលរដ្ឋ ឆ្នាំ២០២៦

Citizen Budget Fiscal Year 2026

ខែកុម្ភៈ ឆ្នាំ២០២៦


MINISTRY OF RURAL


L DEVELOPMENT

# យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១
# រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព
## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០



## បាវចនា ៥

កំណើន | ការងារ | សមធម៌ | ប្រសិទ្ធភាព | ចីរភាព



**១** កំណើនសេដ្ឋកិច្ច ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ

**២** បង្កើតឱកាសការងារ និងពង្រឹងគុណភាពអប់រំ

**៣** កាត់បន្ថយភាពក្រីក្រ ឱ្យនៅក្រោមអត្រា ១0%

**៤** ពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន

**៥** ធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងកសាងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ




## អាទិភាពគន្លឹះ

មនុស្ស | ផ្លូវ | ទឹក | ភ្លើង | បច្ចេកវិទ្យា



# មាតិកា


ក.សេចក្តីផ្តើម ........................................................................ 1

១.ចក្ខុវិស័យ ........................................................................ 2

២.បេសកកម្ម ........................................................................ 2

៣.គោលបំណង និងគោលដៅ ........................................................................ 2

៣.១.គោលបំណង ........................................................................ 2

៣.២.គោលបំណង ........................................................................ 2

៤.យុទ្ធសាស្ត្រ ........................................................................ 2

៥.សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៥ ........................................................................ 3

៦. បញ្ហាប្រឈម ........................................................................ 10

៧.ទិសដៅការងារបន្ត ........................................................................ 11

៨.រចនាសម្ព័ន្ធកម្មវិធី ........................................................................ 11

៨.១.ការអធិប្បាយលម្អិតនូវកម្មវិធីនិមួយៗ ........................................................................ 12

៩.គោលដៅសូចនាករលទ្ធផលចុងក្រោយក្នុងឆ្នាំ២០២៦ ........................................................................ 13

១០.ច្បាប់ថវិកា ឆ្នាំ២០២៦ ........................................................................ 14

១០.១.ការប្រៀបធៀបថវិកាឆ្នាំ២០២៦ និងច្បាប់ថវិកា២០២៥ ........................................................................ 25

១១.យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ........................................................................ 27

១២.សេចក្តីសន្និដ្ឋាន ........................................................................ 27

## ក.សេចក្ដីផ្ដើម

ក្នុងនីតិកាលទី៧ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានបដិសន្ធិឡើងយ៉ាងស្វាហាប់ និងប្រកបដោយភាពជឿជាក់ ឈ្លាសវៃ ឆន្ទៈខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានចក្ខុវិស័យវែងឆ្ងាយ ដើម្បីកាច់ចង្កូតនាវាកម្ពុជាឆ្ពោះទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ **និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០** «**ប្រទេសអភិវឌ្ឍន៍**» តាមរយៈការដាក់ចេញនូវ**យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១** ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព នៅកម្ពុជាដោយឈរលើសសរស្តម្ភគន្លឹះចំនួន៥គឺ **មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យាឌីជីថល** តាមរបៀបវារៈជានាប្រសិទ្ធភាពសមិទ្ធកម្មដោយអនុវត្ត**អភិក្រម ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**។ ឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ខាងលើក្រសួងអភិវឌ្ឍន៍ជនបទ បានកំណត់គោលបំណងគោលនយោបាយចក្ខុវិស័យ បេសកកម្ម និងយុទ្ធសាស្ត្រ គន្លឹះមួយចំនួនសម្រាប់រយៈពេល ១០ ឆ្នាំបន្ត ២០២៥-២០៣៥ និងរៀបចំប្រែក្លាយយុទ្ធសាស្ត្រឱ្យក្លាយទៅជារចនាសម្ព័ន្ធកម្មវិធីអាទិភាពចំនួន៥រួមមាន៖ ទី១.**ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទប្រកបដោយភាពធន់**, ទី២.**ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទ**,ទី៣. **ការជំរុញអភិវឌ្ឍន៍សហគមន៍ជនបទ និងចលនាភូមិគំរូ**, ទី៤. **ការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ** និងទី៥.**ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** ដើម្បីចូលរួមចំណែកឈានទៅសម្រេចគោលបំណងគោលនយោបាយធ្វើឱ្យ "**ប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ សុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្ដីថ្លៃថ្នូរ**" ដោយផ្ដោតទៅលើការអភិវឌ្ឍតំបន់ជនបទឱ្យឆ្លើយតបទៅនឹងតម្រូវការជាអាទិភាព ប្រកបដោយតុល្យភាព ភាពធន់ បរិយាបន្ន និងនិរន្តរភាព ដែលនឹងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរស់នៅរបស់ប្រជាជននៃព្រះរាជាណាចក្រកម្ពុជា។

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានឈានមកដល់ដំណាក់កាលទី៤ "**គណនេយ្យភាពចំពោះសមិទ្ធកម្ម**" គោលដៅប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាជាជំហានៗពីប្រព័ន្ធដែលពឹងលើធាតុចូលមានលក្ខណៈមជ្ឈការឱ្យទៅជាប្រព័ន្ធដែលផ្អែកលើធាតុចេញមានលក្ខណៈវិមជ្ឈការ និងវិសហមជ្ឈការ បានក្លាយជា **ថវិកាព័ត៌មានសមិទ្ធកម្ម** ដែលត្រូវរៀបចំ និងអនុវត្តតាំងឆ្នាំ២០២៣ មក ដោយផ្ដោតសំខាន់ទៅលើការកំណត់សូចនាករលទ្ធផលចុងក្រោយនៃកម្មវិធី (Outcome) និងសូចនាករលទ្ធផលក្នុងឆ្នាំ (Output) ការបញ្ចូលប្រាក់បៀវត្សរ៍ក្នុងកម្មវិធីនីមួយៗ ការរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មទាំងបីកម្រិត និងការរៀបចំអង្គភាពថវិកាពេញលេញ។

ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ និងគោលការណ៍ណែនាំក្នុងការរៀបចំថវិកាសមិទ្ធកម្ម ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំគោលនយោបាយជាតិអភិវឌ្ឍន៍ជនបទឆ្នាំ២០២៥-២០៣៥ និងកំណត់ចក្ខុវិស័យក្នុងការចូលរួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ដើម្បីឆ្លើយតបទៅគោលដៅប្រទេសកម្ពុជាក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

## ១. ចក្ខុវិស័យ

ក្រសួងអភិវឌ្ឍន៍ជនបទមានចក្ខុវិស័យ «**កសាងសង្គមជនបទកម្ពុជាឱ្យមានវិបុលភាព ប្រកបដោយបរិយាបន្ន សមធម៌ និងចីរភាព**» ។

## ២.បេសកកម្ម

ក្រសួងអភិវឌ្ឍន៍ជនបទ មានបេសកកម្ម ដើម្បីបំពេញតួនាទីក្នុងការអនុវត្តកម្មវិធីអាទិភាពទាំង៥ ដោយបង្កើតបានការងារ មុខរបរ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតំបន់ជនបទ ជាពិសេសក៏បានជំរុញកំណើនសេដ្ឋកិច្ចនៅតំបន់ជនបទឱ្យបានឆាប់រហ័ស និងលើកកម្ពស់គុណភាព និងគុណតម្លៃនៃជីវិតរបស់ប្រជាជនជនបទឱ្យបានប្រសើរឡើងតាមរយៈការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគមនាគមន៍ និងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ការអប់រំសុខភាពអនាម័យ ការគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌នៅតាមតំបន់ជនបទ ។

## ៣.គោលបំណង និងគោលដៅ

### ៣.១.គោលបំណង

ដើម្បីឈានទៅសម្រេចចក្ខុវិស័យខាងលើពោលគឺប្រែក្លាយតំបន់ជនបទ នៃព្រះរាជាណាចក្រកម្ពុជា ជាតំបន់អភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់គោលបំណងគោលនយោបាយ **ធ្វើឱ្យបានប្រជាជននៅតំបន់ជនបទមានជីវភាពរស់នៅសមរម្យប្រកបដោយភាពធន់ មានសុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អប្រកបដោយចីរភាព និងមានសេចក្តីថ្លៃថ្នូរ** ដែលនឹងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជានិងជួយជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៣.២.គោលដៅ

ដើម្បីបង្កើនគុណភាពជីវិតរបស់ប្រជាជនឱ្យបានល្អប្រសើរគឺសំដៅដល់ជីវភាពសមរម្យ សុខភាពមាំមួន និងបង្កើនគុណតម្លៃជីវិតនៃជីវិតរបស់ប្រជាជន ធានារក្សាភាពថ្លៃថ្នូររបស់សង្គមជនបទ ពោលគឺជាប្រជាជនដែលមានចំណេះវិជ្ជាមូលដ្ឋាន និងមានគំនិតច្នៃប្រឌិតបង្កើតថ្មីក្នុងការបម្រើគ្រួសារ និងសង្គមជាតិ ដើម្បីជាមូលដ្ឋានក្នុងការរួមចំណែកទៅសម្រេចឱ្យបាននូវគោលបំណង និងចក្ខុវិស័យខាងលើក្រសួងអភិវឌ្ឍន៍ជនបទ បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រចំនួន ៤ ដូចខាងក្រោម៖

- គោលដៅទី១ "**តំបន់ជនបទមានហេដ្ឋារចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នា**"
- គោលដៅទី២ "**ប្រជាជននៅតំបន់ជនបទមានសុខភាពល្អនិងអាយុសង្ឃឹមរស់វែង** "
- គោលដៅទី៣ "**ប្រជាជនរស់នៅក្នុងភូមិឋានដែលមានភាពសុខក្សេមក្សាន្ត និងមានបរិស្ថានល្អ**"
- គោលដៅទី៤ "**ប្រជាជននៅតំបន់ជនបទមានកំណើនប្រាក់ចំណូលប្រកបដោយចីរភាព**"

## ៤.យុទ្ធសាស្ត្រ

ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់យុទ្ធសាស្ត្រសំខាន់ៗចំនួន ៥ ដូចខាងក្រោម៖

- អភិវឌ្ឍនិងថែទាំហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទប្រកបដោយភាពធន់
- ផ្គត់ផ្គង់ទឹកស្អាត និងលើកកម្ពស់អនាម័យជនបទទាំងកម្រិតមូលដ្ឋាន និងកម្រិតសុវត្ថិភាពប្រកបដោយភាពធន់និងបរិយាបន្ន
- អភិវឌ្ឍសហគមន៍ជនបទ ជាពិសេសជំរុញការអភិវឌ្ឍចម្រុះ និងបន្តការអនុវត្តចលនាភូមិមួយផលិតផលមួយ និងចលនាភូមិគំរូប្រកបដោយភាពធន់និងបរិយាបន្ន
- បង្កើនប្រាក់ចំណូលគ្រួសារនៅតំបន់ជនបទប្រកបដោយចីរភាព តាមរយៈពិពិធកម្មមុខរបរ និងនវានុវត្តន៍ការងារ
- លើកកម្ពស់អភិបាលកិច្ច ឌីជីថល និងកិច្ចសហប្រតិបត្តិការ

## ដ្យាក្រាម : ចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយ




## ៥.សមិទ្ធផលសម្រេចបានក្នុងឆ្នាំ ២០២៥

នៅក្នុងឆ្នាំ២០២៥ នេះ ក្រសួងអភិវឌ្ឍន៍ជនបទបានខិតខំយកចិត្តទុកដាក់អនុវត្តការងារតាមផែនការសមិទ្ធកម្មដែលបានគ្រោងទុក និងអនុវត្តតាមកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៥ រវាងក្រសួងអភិវឌ្ឍន៍ជនបទជាមួយនឹងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមតាមគោលការណ៍ពង្រឹង៧០% និងពង្រីក៣០% ដោយសម្រេចបានលទ្ធផលក្នុងឆ្នាំគួរឱ្យកត់សម្គាល់ទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ, ការលើកកម្ពស់ការទទួលបានទឹកស្អាតនិងអនាម័យជនបទ និងការអភិវឌ្ឍសហគមន៍ជនបទនិងចលនាភូមិគំរូ, ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ និងការពង្រឹងការគ្រប់គ្រងស្ថាប័ននិងសេវាគាំទ្រទូទៅ។ សមិទ្ធផលទាំងអស់នេះបាននិងកំពុងចូលរួមចំណែករក្សាស្ថិរភាពនៃការលើកកម្ពស់កម្រិតជីវភាព សុខុមាលភាព គុណតម្លៃនៃជីវិតរស់នៅ និងការអប់រំសីលធម៌សង្គមរបស់ប្រជាជនជនបទ។

**កម្មវិធីទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទ ប្រកបដោយភាពធន់** សម្រេចបានលទ្ធផលប្រមាណ៩៧% នៃផែនការប្រចាំឆ្នាំ ក្រសួងបានស្ថាបនា ពង្រីកវិសាលភាព និងកែលម្អលើកកម្រិតផ្លូវជនបទបានប្រវែង ១ ២៨៩ គ.ម ក្នុងនោះមាន ផ្លូវក្រាលកៅស៊ូពីរជាន់ ប្រវែង ១ ១៩៤ គ.ម, ផ្លូវក្រាលបេតុងប្រវែង ២៨ គ.ម និងផ្លូវល្បាយក្រួស ប្រវែង ៦៧ គ.ម ព្រមទាំងសំណង់សិល្បការគ្រប់ប្រភេទចំនួន ១៧ ៧៥៨ កន្លែង ការថែទាំនិងជួសជុលផ្លូវជនបទបានប្រវែង ៣.៧៤៨ គ.ម ក្នុងនោះរួមមាន ថែទាំខួបប្រវែង ៤០១ គ.ម ថែទាំប្រចាំប្រវែង ៣ ១៩០ គ.ម ជួសជុលបន្ទាន់ចំនួន ៩៥ករណីស្មើនឹងប្រវែង ១៥៧ គ.ម និងជួសជុល សំណង់សិល្បការគ្រប់ប្រភេទចំនួន ៨៤កន្លែង ព្រមទាំងបានដាំកូនឈើសងខាងផ្លូវចំនួន ១៣ ៥៨១ដើម។












ដោយឡែកគិតត្រឹមឆ្នាំ២០២៥នេះ ផ្លូវជនបទបានកើនឡើងប្រវែង ៥០ ៦៤២ គ.ម ក្នុងនោះ ផ្លូវក្រាលកៅស៊ូពីរជាន់ (DBST)ប្រវែង ៧ ២៨៩ គ.ម និងផ្លូវក្រាលបេតុងប្រវែង ១៧៥៨ គ.ម ផ្លូវក្រាលល្បាយក្រួសប្រវែង ៣៤ ៣២៣ គ.ម និងផ្លូវដីសប្រវែង ៧.២៧២ គ.ម ព្រមទាំងសំណង់ សិល្បការ្យគ្រប់ប្រភេទសរុបចំនួន ៥៩ ២៩១កន្លែង ។







**កម្មវិធីទី២៖ ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទ** សម្រេចបានលទ្ធផលប្រមាណ ៩៩%នៃផែនការប្រចាំឆ្នាំ ដោយធានាឱ្យប្រជាជនរស់នៅជនបទមានសុខភាពល្អ និងអាយុសង្ឃឹមរស់ជាមធ្យម របស់មនុស្សម្នាក់ៗមានការកើនឡើងបន្ថែមទៀត ប្រជាជនរស់នៅក្នុងភូមិឋានសុខក្សេមក្សាន្ត និងបរិស្ថានល្អ។ ក្រសួងបានអនុវត្តសកម្មភាពផ្តត់ផ្គង់ ទឹកស្អាតនិងលើកកម្ពស់អនាម័យជនបទ សម្រេចបានលទ្ធផលដូចតទៅ៖







**-ការផ្គត់ផ្គង់ទឹកជនបទ** សម្រាប់ឆ្នាំ២០២៥ ក្រសួងបានផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតកម្រិតមូលដ្ឋានកើនឡើង ២% និងកម្រិតសុវត្ថិភាពកើនឡើង ៤% ដោយបានសាងសង់អណ្តូងស្នប់ចំនួន ១ ៨០១ អណ្តូង,

សាងសង់ស្រះសហគមន៍ចំនួន ១៣០ស្រះ, សាងសង់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ២១៧ប្រព័ន្ធ, សាងសង់ស្ថានីយផលិត ទឹកផឹកសហគមន៍ចំនួន ៣៥ស្ថានីយ, សាងសង់អាងត្រងទឹកភ្លៀងចំនួន ៥៣អាង, ផ្តល់ពាងត្រងទឹកភ្លៀង លក្ខណៈគ្រួសារចំនួន ១ ៤៦៥ពាង, ស្តារប្រឡាយ ប្រវែង ១០ គ.ម,ចែកធុងចម្រុះចំនួន ២៤ ៦៩៤ធុង និងបានផ្សព្វផ្សាយអប់រំ ប្រជាពលរដ្ឋឱ្យយល់ដឹងពីការគ្រប់គ្រង និងប្រើប្រាស់ទឹកស្អាតមាន អ្នកចូលរួម ចំនួន ៩៣៧នាក់។



| | | |
|---|---|---|
| ✓ | អណ្តូង | ចំនួន ១៨០១ អណ្តូង |
| ✓ | ស្រះសហគមន៍ | ចំនួន ១៣០ ស្រះ |
| ✓ | ប្រព័ន្ធចែកចាយទឹក | ចំនួន ២១៧ប្រព័ន្ធ |
| ✓ | ស្ថានីយផលិតទឹកផឹក | ចំនួន ៣៥ស្ថានីយ |
| ✓ | អាងត្រងទឹកភ្លៀង | ចំនួន ៥៣អាង |
| ✓ | ពាងត្រងទឹកភ្លៀង | ចំនួន ១៤៦៥ពាង |
| ✓ | ចែកធុងចម្រោះ | ចំនួន ២៤ ៦៩៤ ធុង |
| ✓ | ស្តារប្រឡាយ | ប្រវែង១០គម |

✓ ទឹកស្អាតមូលដ្ឋាន ២% → ៨៩%
✓ ទឹកសុវត្ថិភាព ៤% → ២៥%

-**ការងារអនាម័យជនបទ** សម្រាប់ឆ្នាំ២០២៥ ក្រសួងសម្រេចបានសេវាអនាម័យកម្រិតមូលដ្ឋានកើនឡើង ៣% ដោយបានសាងសង់បង្គន់អនាម័យតាមខ្នងផ្ទះឯកជនចំនួន ៨ ៧០៧បង្គន់ និងសាងសង់បង្គន់អនាម័យសាធារណៈចំនួន ២៣បង្គន់ ព្រមទាំងបានផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋពីអនាម័យចំនួន ៤ ៧៤៦ នាក់។



✓ ODF = 100% ទូទាំងប្រទេស
✓ ODF Plus រាជធានីភ្នំពេញ និងខេត្តកណ្តាល

| | | |
|---|---|---|
| ✓ | បង្គន់គ្រួសារ | ចំនួន ៨៧០៧ បង្គន់ |
| ✓ | បង្គន់សាធារណៈ | ចំនួន ២៣បង្គន់ |
| ✓ | អប់រំប្រជាពលរដ្ឋ | ចំនួន ៤៧៤៦នាក់ |

✓ អនាម័យមូលដ្ឋាន ៣% → ៩៥%
✓ អនាម័យសុវត្ថិភាព ១៥% → ៥១%

គិតត្រឹមឆ្នាំ២០២៥ ក្រសួងសម្រេចបានការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតកម្រិតមូលដ្ឋាន ៨៩% និងសេវាផ្គត់ផ្គង់ទឹកកម្រិតសុវត្ថិភាព ២៥% ដោយបានសាងសង់អណ្តូងស្នប់ចំនួន ១ ០៦៨ ៦០៤អណ្តូង, ស្រះសហគមន៍ ចំនួន ១០ ៧៥៦ស្រះ, អាងត្រងទឹកភ្លៀងចំនួន ៥៨ ៧១២អាង, ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ចំនួន ៤៦៩ប្រព័ន្ធ. ស្ថានីយផលិតទឹកផឹកសហគមន៍ចំនួន ៥០៧ស្ថានីយ និងស្ថានីយស្រូបយក ទឹកពីបរិយាកាសចំនួន ៥ស្ថានីយ៍ និងបានផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់ដឹងពីការគ្រប់គ្រង និងប្រើប្រាស់ទឹកស្អាតមានអ្នកចូលរួមចំនួន ១៤ ៦៤៣នាក់ ។ ចំណែកការគ្រប់គ្រងសេវាអនាម័យកម្រិតមូលដ្ឋាន ៩៥% និងសេវាអនាម័យកម្រិតសុវត្ថិភាព ៥១% ដោយបានសាងសង់បង្គន់អនាម័យតាមខ្នងផ្ទះឯកជនចំនួន ៣,៣០៨,៣៨០បង្គន់ និងសាងសង់បង្គន់អនាម័យសាធារណៈ ចំនួន ១០ ៥៤៣បង្គន់។ ដោយមានការចូលរួមទាំងថ្នាក់ក្រោមជាតិ អង្គការមិនមែនរដ្ឋាភិបាល និងប្រជាជន ក្រសួងបានសម្រេចបញ្ចប់ការបន្ទាបង់ពាសវាលពាសកាល (OOF) ១០០% ត្រឹមឆ្នាំ២០២៥ ក្នុងក្របខណ្ឌទូទាំងប្រទេសក្នុងនោះរាជធានីភ្នំពេញ និងខេត្តកណ្តាល (ODF Plus) ។

## ផែនទីអត្រាគ្របដណ្ដប់ទឹកស្អាត (WASH-MIS 2025)




## ផែនទីអត្រាគ្របដណ្ដប់អនាម័យ (WASH-MIS 2025)




**សម្រេច ODF 100%**
រាជធានី-ខេត្តទាំង 25 (25 Provinces)

**កម្រិតខ្ពស់ (ODF+)**
រាជធានីភ្នំពេញ និង ខេត្តកណ្ដាល

**សមិទ្ធិផលសរុប**

ភូមិ (Villages) 14,592

ឃុំ-សង្កាត់ (Communes) 1,662

ស្រុក-ក្រុង (Districts) 210




**កម្មវិធីទី៣៖ ការជំរុញការអភិវឌ្ឍសហគមន៍ជនបទនិងចលនាភូមិគំរូ** ក្រសួងសម្រេចបានលទ្ធផល ១០០% នៃផែនការប្រចាំឆ្នាំ។ ក្រសួងអភិវឌ្ឍន៍ជនបទ បានយកចិត្តទុកដាក់ខ្ពស់លើការងារអភិវឌ្ឍន៍នៅតាមសហគមន៍ជនបទនានានៅទូទាំងប្រទេស ដើម្បីធានាឱ្យប្រជាជនរស់នៅក្នុងភូមិឋាន នៃតំបន់ជនបទទទួលបានភាពសុខដុមរមនា សុខក្សេមក្សាន្ត និងបរិស្ថានល្អ។ ជាលទ្ធផលក្នុងឆ្នាំ២០២៥ ក្រសួងបានប្រកាសទទួលស្គាល់ និងប្រគល់វិញ្ញាបនបត្រ «ភូមិគំរូ» ជូនដល់ភូមិជ័យលាភីចំនួន ៥១ភូមិ និងកំពុងអនុវត្តគម្រោងភូមិគំរូចំនួន ៣៤ភូមិបន្ថែមទៀត ក្នុងនោះ «ភូមិសន្តិភាព» ចំនួន ៣០ភូមិ និង «ចលនាភូមិថ្មី» ចំនួន ៤ភូមិ ដែលធ្វើឱ្យចំនួនភូមិគំរូសរុបកើនដល់ចំនួន ១១៥ ភូមិគំរូ។ ក្រៅពីនេះ ក្រសួងបានពង្រឹងសមត្ថភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិបានចំនួន ៤៨៨ភូមិ កើនដល់ចំនួន ៨ ៧៤៧ ភូមិ។ សម្រាប់ការងារត្រី-វិស័យ "កសិកម្ម-ទឹក-ជនបទ" ក្រសួងបានកំណត់យកសហគមន៍គោលដៅអនុវត្តក្នុងឆ្នាំ២០២៥ ចំនួន ៥សហគមន៍ និងបានសិក្សាបញ្ចូលបេក្ខភាពសហគមន៍គោលដៅត្រី-វិស័យឆ្នាំ ២០២៦ ចំនួន ៧សហគមន៍បន្ថែមទៀត។ ក្រសួងបានចេញលិខិតទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចចំនួន ១៤ សហគមន៍ កើនដល់ចំនួន ២១៨ សហគមន៍, រៀបចំបទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រង និងប្រើប្រាស់ដាដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចចំនួន ១០៥សហគមន៍, ចុះផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ចំនួន ៣៨លើក, ចុះពង្រឹងតួនាទី និងរចនាសម្ព័ន្ធគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចចំនួន ៣៣លើក, និងការរៀបចំទិវាជនជាតិដើមភាគតិច ចំនួន ២១លើក។







- ✓ ទទួលស្គាល់ភូមិគំរូ ចំនួន ៥១ភូមិ
- ✓ ពង្រឹងគ.អ.ភ ចំនួន ៤៨៨ភូមិ
- ✓ ផ្តល់ពោងជីកំប៉ុស្ត និងបន្លែចម្រុះ ចំនួន ៤២៥គ្រួសារ
- ✓ ត្រី-វិស័យ ចំនួន ៥សហគមន៍
- ✓ ទទួលស្គាល់អត្តសញ្ញាណជនជាតិដើមភាគតិច ចំនួន១៤សហគមន៍
- ✓ ផ្សព្វផ្សាយគោលនយោបាយជាតិជនជាតិដើម ចំនួន៣៨លើក
- ✓ រៀបចំទិវាជាតិជនជាតិដើមភាគតិច ចំនួន ១លើក សរុប ២១លើក

**កម្មវិធីទី៤៖ ការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ** ក្រសួងសម្រេចបានលទ្ធផលប្រមាណ ៩៨% នៃផែនការប្រចាំឆ្នាំ ដើម្បីចូលរួមបង្កើនប្រាក់ចំណូលរបស់ប្រជាជននៅតំបន់ជនបទ និងលើកកម្រិតជីវភាពរស់នៅដោយផ្ទាល់រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅជនបទ។ តាមរយៈសកម្មភាពជាច្រើនដូចជាការជំរុញបង្កើតការងារ និងមុខរបរនៅជនបទ, ដើម្បីបង្កើនការធ្វើពិពិធកម្មសកម្មភាព សេដ្ឋកិច្ចគ្រួសារ និងស្វែងរកទីផ្សារ លក់ផលិតផលដែលកសិករផលិតបាន។



គិតត្រឹមឆ្នាំ២០២៥ ដើម្បីជំរុញ សកម្មភាពសេដ្ឋកិច្ចគ្រួសារឱ្យកាន់តែផុសផុលឡើង ក្រសួងមានឥណទានសរុបប្រមាណ ២ ២០៥ លានរៀល ដែលបានផ្តល់ឥណទានជូនប្រជាជន ចំនួន ១៥៩នាក់ ក្នុងភូមិគោលដៅចំនួន ៤៣ភូមិ ២២ឃុំ ១២ស្រុក ក្នុងខេត្តចំនួន៩។ ក្រសួងបានសាងសង់ផ្សារសហគមន៍ជនបទចំនួន ៦កន្លែង, ចងក្រងក្រុមសហគមន៍សន្សំប្រាក់ចំនួន ៥១៤០ក្រុម និងបានរៀបចំតាំងពិព័រណ៍ផលិតផលជនបទចំនួន ៧លើក ព្រមទាំងបានបង្កើតសិប្បកម្មផលិតសាប៊ូចំនួន ៦៣កន្លែង។ ក្នុងឆ្នាំ ២០២៥ នេះ ក្រសួងបានបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីបានចំនួន ៦ ៤៦៦នាក់ និងប្រជាពលរដ្ឋចំនួន ៦៦ ៨៥៨នាក់ ដែលគិតត្រឹមឆ្នាំ២០២៥ មន្ត្រីដែលបានទទួលការបណ្តុះបណ្តាលពង្រឹងសមត្ថភាពកើនដល់ចំនួន ៧០ ៥២៨ នាក់ និង ប្រជាពលរដ្ឋកើនដល់ចំនួន ១៥០ ៧៤៧ នាក់ ។

- ✓ បណ្តុះបណ្តាលមន្ត្រីរាជការ ចំនួន ៦ ៤៦៦ នាក់
- ✓ បណ្តុះបណ្តាលប្រជាពលរដ្ឋ ចំនួន ៦៦ ៨៥៨ នាក់
- ✓ បច្ចុប្បន្នមានឥណទាន ចំនួន ២ ២០៥ ៣៥២ ៨០៨រៀល មានអ្នកខ្ចីសរុបចំនួន ១៥៩នាក់ នៅភូមិចំនួន៤៣ ឃុំ២២ ស្រុក១២ និងខេត្តចំនួន៩
- ✓ សាងសង់ផ្សារ ចំនួន៦
- ✓ ចងក្រងក្រុមសហគមន៍កសិក ចំនួន ៥១៤០ក្រុមនិង
- ✓ រៀបចំតាំងពិព័រណ៍ផលិតផលជនបទចំនួន ៧លើក





**កម្មវិធីទី៥៖ ការគ្រប់គ្រងស្ថាប័ននិងសេវាគាំទ្រទូទៅ** ក្រសួងសម្រេចបាន ១០០% នៃផែនការប្រចាំឆ្នាំ។ កម្មវិធីទី៥នេះ គាំទ្រដល់កម្មវិធីទាំង៤ខាងលើ ដោយផ្តោតលើការសហការពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេស ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងស្ថាប័ននានាក្នុងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ព្រមទាំងប្រជាពលរដ្ឋផងដែរ។ ក្រសួងបានចូលរួមអនុវត្តកម្មវិធីកំណែទម្រង់សំខាន់ៗចំនួន៣គឺ៖(១).កំណែទម្រង់រដ្ឋបាលសាធារណៈ (២). កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង(៣). កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងបានធ្វើបញ្ចប់វិភាគមុខងារ និងទទួលបានអនុក្រឹត្យលេខ២៣៧ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ, ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងបាននិងកំពុងអនុវត្តផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាល ទី៤ (MAP4) គណនេយ្យភាពសមិទ្ធកម្ម។

ក្នុងឆ្នាំ២០២៥នេះ ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០៣៥ ដោយទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីនៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥ និងត្រូវបានចុះហត្ថលេខាដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**នាយករដ្ឋមន្ត្រី** នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២៥ ហើយត្រូវបានផ្សព្វផ្សាយកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ ថ្មីៗនេះ ក្រោមអធិបតីភាព **ឯកឧត្តម ឆាយ ឫទ្ធិសែន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទលេខ២៣៧ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥។ ក្រសួងបានរៀបចំវេទិកាថវិកាសាធារណជន (ថវិកាពលរដ្ឋ) និងបានរៀបចំបង្កើតអង្គភាពថវិកាកម្រិតអគ្គនាយកដ្ឋានចំនួន ២ ព្រមទាំងបានរៀបចំកិច្ចព្រមព្រៀងសមិទ្ធកម្មទាំង៣កម្រិតរវាងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ, រវាងក្រសួងអភិវឌ្ឍន៍ជនបទជាមួយនឹងអគ្គនាយកដ្ឋានទាំង២ និងរវាងអគ្គនាយកដ្ឋានទាំង២ ជាមួយនឹងអង្គភាពក្រោមឱវាទ ដើម្បីអនុវត្តឱ្យសម្រេចបានជោគជ័យនូវសូចនាករសមិទ្ធកម្ម។

ចំពោះការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងអភិវឌ្ឍន៍ជនបទបានដំណើរការងារយ៉ាងរលូនដោយបានបន្តផ្តល់សេវាដល់ថ្នាក់ក្រោមជាតិក្នុងទម្រង់នៃការអនុវត្តរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈការធ្វើប្រតិភូកម្មមុខងារចំនួន ៣ ទៅរដ្ឋបាលក្រុង ស្រុកគឺ ទី១.មុខងារផ្តល់សេវាអនាម័យជនបទ ទី២.មុខងារថែទាំ និងជួសជុលសំណង់ផ្គត់ផ្គង់ទឹកស្អាតជនបទគ្រប់ប្រភេទនិងទី៣.មុខងារថែទាំផ្លូវជនបទជាលក្ខណៈប្រចាំចំពោះផ្លូវដែលតភ្ជាប់ពីភូមិទៅភូមិ និងផ្លូវក្នុងភូមិគ្រប់ប្រភេទ លើកលែងតែផ្លូវក្រាលកៅស៊ូ និងបេតុង និងបានរៀបចំនូវវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសលើមុខងារទាំងបីដែលបានផ្ទេរ និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើការអនុវត្តមុខងារទាំង៣របស់រដ្ឋបាលក្រុងស្រុកគោលដៅទាំង២១។ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ក្រសួងបានរៀបចំកិច្ចព្រមព្រៀងជាមួយអង្គការដៃគូចំនួន ៤៤ អង្គការ និងរៀបចំលិខិតគាំទ្រផ្សេងៗ។












សរុបជារួមសម្រាប់ឆ្នាំ២០២៥នេះ ក្រសួងបានអនុវត្តសកម្មភាពតាមរយៈកម្មវិធីអាទិភាពទាំង៥ សម្រេចបានលទ្ធផលជាសារវន្ត តាមរយៈការធ្វើសមាមាត្រនៃលទ្ធផលឆ្លុះបញ្ចាំងជាមួយសូចនាករ និងគោលដៅសមិទ្ធកម្មដែលបានកំណត់ក្នុងឆ្នាំ២០២៥ ក្នុងនោះមានការអនុវត្តការចំណាយថវិកាចំនួន៩៧% សម្រេចគោលដៅបានចំនួន ៩៩%។ ការអនុវត្តថវិកា សម្រេចបានខ្ពស់ជាងឆ្នាំ២០២៤ (៩១%) ចំនួន ៦% បើប្រៀបធៀប ជាមួយឆ្នាំ២០២៥ (៩៧%) និងសម្រេចគោលដៅខ្ពស់ជាងឆ្នាំ២០២៤ (៩៨%) ចំនួន ១% បើប្រៀបធៀបជាមួយឆ្នាំ២០២៥ (៩៩%)។

- ✓ សម្រេចគោលដៅខ្ពស់ជាងឆ្នាំ២០២៤ ចំនួន ១%
- ✓ ការអនុវត្តថវិកាខ្ពស់ជាងឆ្នាំ២០២៤ ចំនួន ៦%







## ៦. បញ្ហាប្រឈម

ទន្ទឹមនឹងការសម្រេចបានសមិទ្ធផលជាច្រើន ក្រសួងក៏បាននិងកំពុងជួបប្រទះនូវបញ្ហាការប្រឈមមួយចំនួនក្នុងដំណើរការអភិវឌ្ឍដែលទាមទារឱ្យមានការដោះស្រាយជាប្រព័ន្ធ និងទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ ក្នុងការឆ្លើយតបទៅនឹងសេចក្ដីត្រូវការជាក់ស្ដែងរបស់ប្រជាជនជនបទសំដៅកាត់បន្ថយភាពក្រីក្រ ព្រមទាំងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទផងដែរ។ ជាមួយ គ្នានេះក្រសួងបានកត់សម្គាល់ឃើញមានបញ្ហាមួយចំនួន បាននិងកំពុងកើតមានឡើងនៅតាមមូលដ្ឋានរាជធានី-ខេត្ត ដែលបង្កឱ្យមានការប្រឈមមួយចំនួនក្នុងដំណើរការអភិវឌ្ឍន៍ជនបទជាអាទិ៍៖



## ៧.ទិសដៅការងារបន្ត

ផ្អែកលើគោលនយោបាយ បណ្ដាបញ្ហា និងការប្រឈមខាងលើ ក្រសួងអភិវឌ្ឍន៍ជនបទ បាន ដាក់ចេញនូវសកម្មភាពការងារតាមកម្មវិធីអាទិភាព ជាទិសដៅបន្តសម្រាប់អនុវត្តនៅឆ្នាំ២០២៦ ដូចតទៅ៖




## ៨.រចនាសម្ព័ន្ធកម្មវិធី

ដើម្បីសម្រេចបាននូវចក្ខុវិស័យ**កសាងសង្គមជនបទកម្ពុជា ឱ្យមានវិបុលភាព ប្រកបដោយបរិយាបន្ន និងចីរភាព**” និងការចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលកម្ពុជាក្នុង នីតិទី៧ នៃរដ្ឋសភា ក្នុងឆ្នាំ២០២៦ នេះក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំអនុវត្តកម្មវិធីចំនួន៥ អនុកម្មវិធី ចំនួន ៣០ (ក្នុងនោះ ថ្នាក់ខេត្ត មានចំនួន ៥ អនុកម្មវិធី) និងចង្កោមសកម្មភាពចំនួន២៣៣ (ក្នុងនោះ ក្រសួងមានចំនួន ១០៨ មន្ទីររាជធានី-ខេត្តមានចំនួន ១២៥) ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងចាប់ផ្តើមអនុវត្ត អង្គភាពថវិកាចំនួន ២ កម្រិតអគ្គនាយកដ្ឋានគឺអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋាន បច្ចេកទេស មានអង្គភាពថវិកាសរុប ២៧ ដែលក្នុងនោះមានចំនួន ២៥ ជាអង្គភាពថវិកាអាណាប័កផ្ទេរ សិទ្ធពេញលេញ និង ២ ជាកម្រិតអគ្គនាយកដ្ឋានជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធមិនពេញលេញដែល មានរចនាសម្ព័ន្ធកម្មវិធីមានដូចខាងក្រោម ៖



## ៨.១.ការអធិប្បាយលម្អិតនូវកម្មវិធីនីមួយៗ

| ឈ្មោះកម្មវិធី | ការពន្យល់លម្អិតអំពីកម្មវិធី |
|---|---|
| **កម្មវិធីទី១៖ "ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ប្រកបដោយភាពធន់"**<br>**គោលបំណងកម្មវិធីទី១៖** ធ្វើឱ្យប្រសើរស្ថានភាពផ្លូវជនបទតាមរយៈការបង្កើនគុណភាព និងការតភ្ជាប់ផ្លូវតំបន់ជនបទធានាការប្រើប្រាស់គ្រប់រដូវកាល ដើម្បីរួមចំណែកលើកកម្ពស់ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ។ | ពិតជាមានសារៈសំខាន់ណាស់ក្នុងការជំរុញដំណើរអន្តរកម្មផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចរវាងតំបន់ជនបទ និងទីប្រជុំជន/ទីក្រុង។ វិស័យផ្លូវជនបទបានដើរតួជាសរសៃឈាមសេដ្ឋកិច្ចដ៏សំខាន់ក្នុងការផ្សារភ្ជាប់នូវសកម្មភាពធុរកិច្ចផ្សេងៗក្នុងតំបន់ឱ្យមានភាពរស់រវើក និងកាន់តែសកម្មឡើងថែមទៀត ដែលជាមូលដ្ឋានគ្រឹះក្នុងការជំរុញកំណើនប្រាក់ចំណូលរបស់ប្រជាជននៅជនបទ |
| **កម្មវិធីទី២៖ "ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទ"**<br>**គោលបំណងកម្មវិធីទី២៖**លើកកម្ពស់លក្ខខណ្ឌ នៃការរស់នៅរបស់សហគមន៍ជនបទតាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ | កែលម្អសុខមាលភាពនៃការរស់នៅប្រចាំថ្ងៃរបស់ប្រជាជននៅតាមជនបទឱ្យបានល្អប្រសើរឡើង ដើម្បីកាត់បន្ថយជំងឺផ្សេងៗមួយចំនួនដែលបណ្តាលមកពីការរស់នៅគ្មានអនាម័យ ការប្រើប្រាស់ និងបរិភោគទឹកមិនស្អាតរស់ក្នុងបរិស្ថានមិនល្អ ការបំពុលបរិស្ថាន ការបោលសំរាម ការបន្ទោរបង់ពាសវាលពាសកាល ។ល។ |
| **កម្មវិធីទី៣៖ "ការជំរុញអភិវឌ្ឍសហគមន៍ជនបទ និងចលនាភូមិគំរូ"**<br>**គោលបំណងកម្មវិធីទី៣៖**ធ្វើការអភិវឌ្ឍភូមិចម្រុះឱ្យក្លាយទៅជាភូមិគំរូ និងការងារជនជាតិដើមភាគតិចត្រូវបានទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច និងធ្វើការអភិរក្សព្រមទាំងអភិវឌ្ឍជនជាតិដើមភាគតិច | ធ្វើការអភិវឌ្ឍភូមិចម្រុះឱ្យប្រែក្លាយទៅជាភូមិគំរូ ការងារ ជនជាតិដើមភាគតិចត្រូវបានទទួលស្គាល់អត្តសញ្ញាណ សហគមន៍ជនជាតិដើមភាគតិច និងធ្វើការអភិរក្ស ព្រមទាំងអភិវឌ្ឍជនជាតិដើមភាគតិច។ |
| **កម្មវិធីទី៤៖ "ការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ"**<br>**គោលបំណងកម្មវិធីទី៤៖**លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទឱ្យបានល្អប្រសើរ និងបណ្តុះបណ្តាលប្រជាពលរដ្ឋជនបទឱ្យមានជំនាញមូលដ្ឋានអាជីព | គឺជាកម្លាំងចលករមួយកំពុងរួមចំណែកយ៉ាងសកម្មក្នុងការជំរុញឱ្យមានការផ្លាស់ប្តូរជីវភាពរស់នៅរបស់ប្រជាជនជនបទ តាមរយៈការបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការផ្តល់ឥណទានខ្នាតតូច ការបង្កើតមុខរបរខ្នាតតូច ។ |
| **កម្មវិធីទី៥៖ "ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ"**<br>**គោលបំណងកម្មវិធីទី៥៖** គាំទ្រដល់គ្រប់សកម្មភាពការងារ និងសេវានានាក្នុងការធានា និងជំរុញឱ្យការអនុវត្តផែនការសកម្មភាពការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ប្រកបដោយប្រសិទ្ធិភាព។ | ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងក្រសួងគាំទ្រដល់កម្មវិធីអភិវឌ្ឍធនធានមនុស្ស និងអភិបាលកិច្ចល្អ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ សំដៅរួមចំណែកក្នុងការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកែទម្រង់ដទៃទៀតឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ |

## ៩.គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ២០២៦

ដើម្បីសម្រេចបានជោគជ័យ ក្រសួងអភិវឌ្ឍន៍ជនបទបានកំណត់គោលដៅសូចនាករលទ្ធ ក្នុងឆ្នាំចំនួន ១៤ មានបញ្ជាក់ខាងក្រោម ដូចខាងក្រោម ៖

| សូចនាករគន្លឹះ | | ខ្នាតរង្វាស់ | ២០២៦ |
|---|---|---|---|
| | | | គោលដៅ |
| **កម្មវិធីទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងគមនាគមន៍ជនបទប្រកបដោយភាពធន់** | | | |
| **គោលបំណងកម្មវិធីទី១៖**ធ្វើឱ្យប្រសើរស្ថានភាព ផ្លូវជនបទតាមរយៈការបង្កើនគុណភាព និងការតភ្ជាប់ផ្លូវតំបន់ជនបទជានាការប្រើប្រាស់គ្រប់រដូវកាល ដើម្បីរួមចំណែកលើកកម្ពស់ស្ថានភាព សេដ្ឋកិច្ច និងសង្គមកិច្ច ។ | ប្រវែងផ្លូវជនបទ ដែលត្រូវបានស្ថាបនាដោយក្រាលកៅស៊ូពីរជាន់ DBST | គ.ម | ៤២,៩ |
| | ប្រវែងផ្លូវជនបទ ដែលត្រូវបានស្ថាបនាបេតុង | គ.ម | ២៨,៤ |
| | ប្រវែងផ្លូវជនបទដែលត្រូវបានស្ថាបនាដោយក្រាលដីល្បាយក្រួស | គ.ម | ១០៨,១ |
| | ប្រវែងផ្លូវជនបទដែលត្រូវបានថែទាំជាលក្ខណៈខួប ប្រចាំ និងបន្ទាន់ | គ.ម | ៣ ២៦៦ |
| **កម្មវិធីទី២៖ ការលើកកម្ពស់ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថានជនបទ** | | | |
| **គោលបំណងកម្មវិធីទី២៖**លើកកម្ពស់លក្ខខណ្ឌនៃការរស់នៅរបស់សហគមន៍ជនបទតាមរយៈការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។ | ចំនួនគ្រួសារទទួលផលពីអ្នកប្រើប្រាស់អណ្តូងទឹកដែលត្រូវបានសាងសង់ | គ្រួសារ | ៤១ ០០ |
| | ចំនួនគ្រួសារទទួលផលពីអ្នកប្រើប្រាស់ស្រះសហគមន៍ដែលត្រូវបានសាងសង់ | គ្រួសារ | ១ ២០០ |
| | ចំនួនអ្នកទទួលផលពីអ្នកប្រើប្រាស់ប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ខ្នាតតូចសហគមន៍ ដែលត្រូវបានសាងសង់ | គ្រួសារ | ៤៥០ |
| | ចំនួនគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យ | គ្រួសារ | ២ ៥៥០ |
| **កម្មវិធីទី៣៖ ការជំរុញអភិវឌ្ឍសហគមន៍ជនបទ និងចលនាភូមិគំរូ** | | | |
| **គោលបំណងកម្មវិធីទី៣៖**ធ្វើការអភិវឌ្ឍភូមិឱ្យប្រែក្លាយទៅជាភូមិគំរូការងារជនជាតិដើមភាគតិចត្រូវបានទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច និងធ្វើការអភិក្រ្ស ព្រមទាំងអភិវឌ្ឍជនជាតិដើមភាគតិច | អត្រាភូមិជនបទត្រូវបានអភិវឌ្ឍន៍ចម្រុះឱ្យក្លាយទៅជាភូមិគំរូ | ភាគរយ | ០,៤៨ |
| | ចំនួនសហគមន៍ជនជាតិដើមភាគតិចត្រូវបានកំណត់អត្តសញ្ញាណ | សហគមន៍ | ១៤ |
| **កម្មវិធីទី៤៖ ការលើកកម្ពស់ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ** | | | |
| **គោលបំណងកម្មវិធីទី៤៖**លើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទឱ្យបានល្អប្រសើរ និងបណ្តុះបណ្តាលប្រជាពលរដ្ឋជនបទឱ្យជំនាញមូលដ្ឋានអាជីព | អត្រាប្រជាពលរដ្ឋក្នុងភូមិគោលដៅនៅជនបទមានការងារ និងមុខរបរបន្ថែមក្រោយវគ្គបណ្តុះបណ្តាល | ភាគរយ | ១៥,៨៧ |
| | អត្រាប្រជាជននៅជនបទដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានដោយជោគជ័យ | ភាគរយ | ៩៦ |

| សូចនាករគន្លឹះ | | ខ្នាតរង្វាស់ | ២០២៦ |
|---|---|---|---|
| | | | គោលដៅ |
| **កម្មវិធីទី៥៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | | | |
| **គោលបំណងកម្មវិធីទី៥៖**គាំទ្រដល់គ្រប់សកម្មភាពការងារ និងសេវានានាក្នុងការជានា និងជំរុញឱ្យការអនុវត្តផែនការសកម្មភាពការងាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ប្រកបដោយប្រសិទ្ធិភាព។ | ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង | គុណភាព | ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុងត្រូវបានពង្រឹង |
| | ភាគរយនៃការអនុវត្តថវិកាធៀបនឹងច្បាប់ប្រចាំឆ្នាំ | គុណភាព | ធំជាងឬស្មើ ៩៥ ភាគរយ ធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ |

## ១០.ច្បាប់ថវិកាឆ្នាំ២០២៦

ក្នុងការសម្រេចឱ្យបាននូវគោលបំណងគោលនយោបាយ កម្មវិធី និងសូចនាករខាងលើក្រសួងអភិវឌ្ឍន៍ជនបទ បានទទួលឥណទានក្របខណ្ឌថវិកាឆ្នាំ២០២៦ សរុបចំនួន **៣៧៤ ៩៨២ លានរៀល (បីរយចិតសិបបួនពាន់ ប្រាំបួនរយប៉ែតសិបពីរលានរៀល)** កើនឡើង **០,០២%** ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៥ ដែលមានចំនួន **៣៧៤ ៩១១** លានរៀល **(បីរយចិតសិបបួនពាន់ ប្រាំបួនរយដប់មួយលានរៀល)** ដោយក្នុងនោះថវិកាចរន្តក្នុងឆ្នាំ២០២៦ ក្រសួងមានចំនួន **២២៤ ៨៩៧ លានរៀល (ពីររយម្ភៃបួនពាន់ ប្រាំបីរយកៅសិបប្រាំពីរលានរៀល)** កើនឡើង **០,០៣%** ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៥ (ថ្នាក់កណ្តាលមានថវិកាចំនួន **១៧២ ៣២១ លានរៀល (មួយរយចិតសិបពីរពាន់ បីរយម្ភៃមួយលានរៀល)** កើនឡើង ០,០៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៥ និងថ្នាក់រាជធានី ខេត្តថវិកាសរុបចំនួន **៥២ ៥៧៦ លានរៀល (ហាសិបពីរពាន់ ប្រាំរយចិតសិបប្រាំមួយលានរៀល)** ថយចុះ-០,១៧% ធៀបនឹងច្បាប់ថវិកា ឆ្នាំ២០២៥) និងថវិកាវិនិយោគជំពូក២១ ទទួលបានថវិកាចំនួន **១៥០ ០០០ លានរៀល (មួយរយហាសិបពាន់លានរៀល)** ស្មើនឹងច្បាប់ថវិកាឆ្នាំ២០២៥ ដោយឡែកជំពូក ៦៤ ត្រូវបានរៀបចំទៅតាមកកម្មវិធីសរុបចំនួន **៣៨ ២៥៧ លានរៀល (សាមសិបប្រាំពាន់ ពីររយហាសិបប្រាំពីរលានរៀល)** ថ្នាក់កណ្តាលថវិកាចំនួន **១៩ ៣៨២ លានរៀល (ដប់ប្រាំបួនពាន់ បីរយ ប៉ែតសិបពីរលានរៀល)** កើនឡើង ១២៣ លានរៀល (មួយម្ភៃបីលានរៀល) ស្មើនឹង**០,៦%** និងថ្នាក់មន្ទីររាជធានី ខេត្ត ទទួលបានថវិកាចំនួន **១៨ ៨៧៥ លានរៀល (ដប់ប្រាំបីពាន់ ប្រាំបីរយចិតសិបប្រាំលានរៀល)** ថយចំនួន **-២៥២ លានរៀល (ដកពីររយហាសិបពីរលានរៀល** ) ស្មើនឹង-១,៣% ដូចមានតារាងសង្ខេបថវិកាសមិទ្ធកម្មឆ្នាំ២០២៦ ៖

| **កូដកម្មវិធី** | **បរិយាយ** | **ឥណទាន ២០២៥** (N-1 ) | **ឥណទាន ២០២៦** ( N ) | **ធៀបធៀប ឆ្នាំ២០២៥** |
|---|---|---|---|---|
| គោលបំណងគោលនយោបាយ៖ ប្រជាជននៅតំបន់ជនបទមានជីវភាពសមរម្យ សុខភាពមាំមួន រស់នៅក្នុងបរិស្ថានល្អ និងរស់នៅក្នុងសេចក្តីថ្លៃថ្នូរ | | **374,911.0** | **374,982.0** | **0.02%** |
| 1 | **កម្មវិធីទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគមនាគមន៍ជនបទប្រកបដោយភាពធន់** | **299,214.9** | **304,071.5** | **1.6%** |
| **101** | **អនុកម្មវិធីទី១៖ ការជួសជុល និងរក្សាគុណភាពផ្លូវជនបទ** | **132,902.8** | **132,902.8** | **ស្មើច្បាប់** |
| 10101 | ចង្កោមសកម្មភាពទី១៖ ការថែទាំផ្លូវជាលក្ខណៈខួប | 55,995.9 | 55,995.9 | ស្មើច្បាប់ |

| កូដកម្មវិធី | បរិយាយ | ឥណទាន ២០២៥ ( N-1 ) | ឥណទាន ២០២៦ ( N ) | ប្រៀបធៀប ឆ្នាំ២០២៥ |
|---|---|---|---|---|
| 10102 | ចង្កោមសកម្មភាពទី២៖ ការថែទាំផ្លូវជាលក្ខណៈប្រចាំ | 66,561.5 | 66,561.5 | ស្មើច្បាប់ |
| 10103 | ចង្កោមសកម្មភាពទី៣៖ ការជួសជុលផ្លូវជាលក្ខណៈបន្ទាន់ | 10,345.4 | 10,345.4 | ស្មើច្បាប់ |
| **102** | **អនុកម្មវិធីទី២៖ ការពង្រីកវិសាលភាពនៃការស្ថាបនា លើកកម្រិតហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទ** | **150,000.0** | **150,000.0** | **ស្មើច្បាប់** |
| 10201 | ចង្កោមសកម្មភាពទី១៖ ការស្ថាបនា និងកែលម្អផ្លូវជនបទ (ជំពូក២១) | 150,000.0 | 150,000.0 | ស្មើច្បាប់ |
| 10202 | ចង្កោមសកម្មភាពទី២៖ ការស្ថាបនាសំណង់សិល្បការ្យ | - | - | - |
| 10203 | ចង្កោមសកម្មភាពទី៣៖ ការរាប់ចំនួនចរាចរណ៍ | - | - | - |
| 10204 | ចង្កោមសកម្មភាពទី៤៖ គ្រប់គ្រងការងារសង្គម បរិស្ថាន និងសុវត្ថិភាពផ្លូវជនបទ | - | - | - |
| **103** | **អនុកម្មវិធីទី៣៖ ការគ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទ តាមប្រព័ន្ធព័ត៌មានវិទ្យា** | **117.5** | **117.5** | **ស្មើច្បាប់** |
| 10301 | ចង្កោមសកម្មភាពទី១៖ ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងប្រព័ន្ធព័ត៌មានបច្ចេកវិទ្យា | 73.1 | 73.1 | ស្មើច្បាប់ |
| 10302 | ចង្កោមសកម្មភាពទី២៖ ការស្រង់ទិន្នន័យផ្លូវជនបទនិងការធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌផ្លូវជនបទក្នុងប្រព័ន្ធ | 44.4 | 44.4 | ស្មើច្បាប់ |
| **104** | **អនុកម្មវិធីទី៤៖ ការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាប្រកបដោយភាពធន់** | - | - | - |
| 10401 | ចង្កោមសកម្មភាពទី១៖ ពង្រឹងការសិក្សាគ្រោងប្លង់ | - | - | - |
| 10402 | ចង្កោមសកម្មភាពទី២៖ សិក្សា និងពិសោធន៍ពីបច្ចេកវិទ្យាមានភាពធន់ | - | - | - |
| **105** | **អនុកម្មវិធីទី៥៖ ត្រួតពិនិត្យគុណភាព និងសុវត្ថិភាពផ្លូវជនបទ** | **-** | **2,355.9** | **ស្មើច្បាប់** |
| 10501 | ចង្កោមសកម្មភាពទី១៖ ការត្រួតពិនិត្យ និងវាយតម្លៃការងារសាសង់ និងកែលម្អផ្លូវជនបទ | - | - | - |
